ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០៨៥/២១ ក.ប/ស.ស.ក.ប.ស.ស

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពក្រុមការងារ សុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិសន្តិសុខសង្គម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញសេចក្តីសម្រេចលេខ០០២/១៣ ក.ប/ស.ស.រ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញសេចក្តីសម្រេចលេខ០០៤/១៤ ក.ប/ស.ស.រ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១**.-

ត្រូវបានកែសម្រួលសមាសភាពរបស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិសន្តិសុខសង្គម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - ឯកឧត្តម **អ៊ុក សមវិទ្យា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - ឯកឧត្តម **ព្រាប ច័ន្ទវិបុល** | ទីប្រឹក្សាក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| - លោកវេជ្ជបណ្ឌិត **នាង ភារិទ្ធ** | អគ្គនាយករងបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល | អនុប្រធាន |
| - លោកស្រីវរសេនីយ៍ទោ **លឹម សុខជា** | អនុប្រធាននាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| - ឯកឧត្តម **ហេង សុផាន់ណារិទ្ធ** | អគ្គនាយករងបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - ឯកឧត្តម **ឈួន ម៉័ន** | សមាជិកក្រុមការងារសហភាពសហព័ន្ធយុវជនកម្ពុជាក្នុងវិស័យសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - លោកជំទាវ **មុំ ចន្ធី** | នាយិការងនាយកដ្ឋានសុខភាព នៃកាកបាទក្រហមកម្ពុជា | សមាជិកា |
| - លោក **ភាំង ម៉ូនីកា** | អគ្គលេខាធិការរង នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | សមាជិក |
| - លោក **អ៊ុក សំអូន** | ប្រធាននាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ នៃបេឡាជាតិសន្តិសុខសង្គម | សមាជិក |
| - លោក **ភាំង លាងគ្រី** | នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស នៃសាលារាជធានីភ្នំពេញ | សមាជិក |
| - លោកស្រី **ប៊ុច្ឆា ផានី** | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន នៃមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ | សមាជិកា |

| | | |
|---|---|---|
| - លោកវរសេនីយ៍ទោ **តួង ម៉ាលី** | នាយរងការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃការិយាល័យចរាចរណ៍ផ្លូវគោករាជធានីភ្នំពេញ | សមាជិក |
| - លោក **គង់ អាទិត្យ** | អនុប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា | សមាជិក |
| - លោក **លាង ស៊ុនហ៊ាង** | សមាជិកក្រុមប្រឹក្សាភិបាល នៃសភាសម្ព័ន្ធសហជីពជាតិកម្ពុជា | សមាជិក |
| - លោក **យឹង វិទ្ធី** | អនុប្រធានប្រចាំប្រទេស នៃអង្គការជនពិការអន្តរជាតិកម្ពុជា | សមាជិក |
| - លោក **គីម បញ្ញា** | នាយកអង្គការមូលនិធិបង្ការរបួសអាស៊ី ប្រចាំប្រទេសកម្ពុជា | សមាជិក |
| - លោក **យ៉ាម យុទ្ធា** | អនុប្រធាននាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ នៃបេឡាជាតិសន្តិសុខសង្គម | សមាជិក |
| - លោក **ចាយ សំណាង** | អនុប្រធាននាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ នៃបេឡាជាតិសន្តិសុខសង្គម | លេខាធិការ |

**ប្រការ២ .–**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- សាមីអង្គភាព "ដើម្បីជ្រាប"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**បេឡាជាតិសន្តិសុខសង្គម**

លេខ :...៧៤៥/២១...ប.ស.ស.

ខុទ្ទកាល័យរដ្ឋមន្ត្រី
ចូល 5077
23 ខែ 11 ឆ្នាំ 21
11h00

**កំណត់បង្ហាញ**

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ** ៖ សំណើសុំហត្ថលេខាលើសេចក្តីសម្រេចស្តីពី ការកែសម្រួលសមាសភាពក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិសន្តិសុខសង្គម។

**យោង** ៖ សេចក្តីសម្រេចលេខ ០០២/១៣ ក.ប/ស.ស.រ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត។

| **យោបល់សម្រេចឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** | |
|---|---|
| Vu Ms 23/11 | សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន នៃបេឡាជាតិសន្តិសុខសង្គម មានសមាសភាពមួយចំនួនត្រូវបានផ្លាស់ប្តូរ និងសមាសភាពមួយចំនួនបានប្តូរតួនាទីនៅក្នុងស្ថាប័នរបស់ខ្លួន ដូច្នេះ ប.ស.ស. ស្នើសុំរៀបចំកែសម្រួលសមាសភាពក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ដូចមានសេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាពក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត គោរពជូនភ្ជាប់មកជាមួយ។<br>អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេចដោយសេចក្តីអនុគ្រោះ។<br>សូម **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។<br>ថ្ងៃ.........ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥<br>រាជធានីភ្នំពេញ ថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ២០២១<br>**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**<br>**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**<br>**អ៊ុក_សមវិទ្យា** |